# កម្រងសិទ្ធិ នៃអ្នកបោះឆ្នោត

## អ្នកមានសិទ្ធិនៅខាងក្រោមៈ

1. **សិទ្ធិដើម្បីបោះឆ្នោត បើសិនអ្នកជាអ្នកបោះឆ្នោតបានចុះឈ្មោះ។** អ្នកមានសិទ្ធិបោះឆ្នោត បើសិនអ្នកៈ
   - ជាពលរដ្ឋអាមេរិក កំពុងរស់នៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ា
   - មានអាយុយ៉ាងតិចបំផុត 18 ឆ្នាំ
   - បានចុះឈ្មោះនៅកន្លែងដែលអ្នករស់នៅបច្ចុប្បន្ន
   - មិនជាប់ពន្ធនាគារ ឬបិតក្នុងការព្យួរទោស សំរាប់បទឧក្រិដ្ឋ

2. **សិទ្ធិដើម្បីបោះឆ្នោត បើអ្នកជាអ្នកបោះឆ្នោតបានចុះឈ្មោះ សូម្បីតែឈ្មោះ របស់អ្នកមិននៅក្នុងបញ្ជីក៏ដោយ។** អ្នកនឹងបោះឆ្នោតដោយប្រើសន្លឹកឆ្នោតបណ្ដោះអាសន្ន។ ឆ្នោតរបស់អ្នកនឹងបានរាប់ បើមន្ត្រីបោះឆ្នោត សំរេចថាអ្នកមានសិទ្ធិបោះឆ្នោត។

3. **សិទ្ធិដើម្បីបោះឆ្នោត បើអ្នកនៅតែឈរក្នុងជួរ នៅពេលកន្លែងបោះឆ្នោតបិទ។**

4. **សិទ្ធិដើម្បីបោះសន្លឹកឆ្នោតសំងាត់** ដោយគ្មានអ្នកណាម្នាក់រំខានដល់អ្នក ឬប្រាប់អ្នកពីរបៀបបោះឆ្នោត។

5. **សិទ្ធិដើម្បីទទួលសន្លឹកឆ្នោតថ្មី បើអ្នកបានធ្វើដោយភាន់ច្រឡំ** បើអ្នកមិនទាន់បានបោះសន្លឹកឆ្នោតរបស់អ្នកនៅឡើយ។ អ្នកអាចៈ

   **ស្នើសុំមន្ត្រីបោះឆ្នោត នៅកន្លែងបោះឆ្នោត** នូវសន្លឹកឆ្នោតថ្មី; ឬ

   **ដូរសន្លឹកឆ្នោត បោះឆ្នោត-តាម-សំបុត្រ របស់អ្នក** សំរាប់សន្លឹកឆ្នោតថ្មី នៅឯការិយាល័យបោះឆ្នោត ឬនៅឯកន្លែងបោះឆ្នោតរបស់អ្នក; ឬ

   **បោះឆ្នោតដោយប្រើសន្លឹកឆ្នោតបណ្ដោះអាសន្ន** បើអ្នកពុំមានសន្លឹកឆ្នោត បោះឆ្នោត-តាម-សំបុត្រ ដើមរបស់អ្នក។

6. **សិទ្ធិដើម្បីទទួលជំនួយ ក្នុងការបោះសន្លឹកឆ្នោតរបស់អ្នក** ពីជនណាម្នាក់ដែលអ្នកជ្រើសរើស លើកលែងតែពីនិយោជក ឬអ្នកតំណាងសហជីពរបស់អ្នក។

7. **សិទ្ធិដើម្បីប្រគល់សន្លឹកឆ្នោត បោះឆ្នោត-តាម-សំបុត្ររបស់អ្នក ដែលបានបំពេញនៅកន្លែងបោះឆ្នោតណាមួយ** នៅក្នុងខោនធីដែលអ្នកបានចុះឈ្មោះបោះឆ្នោត។

8. **សិទ្ធិដើម្បីទទួលសំភារៈការបោះឆ្នោត ជាភាសាមួយក្រៅពីអង់គ្លេស** បើមានប្រជាជនគ្រប់គ្រាន់នៅក្នុងតំបន់បោះឆ្នោតរបស់អ្នក និយាយភាសានោះ។

9. **សិទ្ធិដើម្បីសួរសំណួរទៅមន្ត្រីបោះឆ្នោត អំពីទំរង់ការបោះឆ្នោត** និងឃ្លាំមើលដំណើរការបោះឆ្នោត។ បើមនុស្សដែលអ្នកសួរ មិនអាចឆ្លើយសំណួររបស់អ្នកបានទេ គេត្រូវតែ បញ្ជូនអ្នកទៅមនុស្សត្រឹមត្រូវដែលអាចឆ្លើយសំណួរបាន។ បើអ្នកមានបូកពាអុកឡុក គេអាចឈប់ឆ្លើយសំណួរអ្នក។

10. **សិទ្ធិដើម្បីរាយការណ៍សកម្មភាពខុសច្បាប់អ្វីមួយ ឬការបោះឆ្នោតដោយគៃបន្លំ** ទៅមន្ត្រីបោះឆ្នោត ឬការិយាល័យរបស់រដ្ឋលេខាធិការ។
    - តាមវ៉ិបសៃត៍ នៅ **www.sos.ca.gov**
    - តាមទូរស័ព្ទ លេខ **(888) 345-4917**
    - តាមអ៊ីមែល **elections@sos.ca.gov**

**បើអ្នកជឿថាអ្នកត្រូវបានបដិសេធនូវសិទ្ធិណាមួយទាំងនេះ** ទូរស័ព្ទទៅលេខពិសេសអ្នកបោះឆ្នោតរបស់រដ្ឋលេខាធិការ តាមលេខឥតចេញថ្លៃជាសំងាត់ **(888) 345-4917។**